## សេចក្ដីសង្ខេបអំពីគម្រោង

គម្រោងពង្រឹងសិទ្ធិអំណាចសហគមន៍តាមរយៈការទទួលបានដីគឺជាគម្រោងសម្បទានដីសង្គមកិច្ចដែលកំពុងត្រូវបានអនុវត្តដោយអង្គការជីវិតថ្លៃថ្នូរ ក្រោមជំនួយឧបត្ថម្ភរបស់មូលនិធិអភិវឌ្ឍន៍សង្គមនៃប្រទេសជប៉ុនតាមរយៈធនាគារពិភពលោក។

គម្រោងនេះមានបីផ្នែកធំៗ៖

**ផ្នែក ក ៖** ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និងកសាងសមត្ថភាពអំពីការអនុវត្តកម្មវិធីដីសម្បទានសង្គមកិច្ច។

**ផ្នែក ខ ៖** ពង្រឹងសិទ្ធិអំណាចសហគមន៍និងអ្នកទទួលដី ដើម្បីឲ្យមានសមត្ថភាពអាចគ្រប់គ្រងដំណើរការអភិវឌ្ឍនិងហ៊ានតស៊ូមតិទាមទារនូវសិទ្ធិរបស់ខ្លួន ព្រមទាំងទទួលបាននូវជីវភាពរស់នៅកាន់តែប្រសើរឡើង និងប្រកបដោយនិរន្តរភាព។

**ផ្នែក គ ៖** កសាងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាល សម្របសម្រួលនិងចែករំលែកមេរៀននិងបទពិសោធន៍។

រយៈពេលអនុវត្តគម្រោង ៖ ២០០៨ - ២០១៣

ថវិកាសរុបសម្រាប់អនុវត្តគម្រោងមាន៖
**១.៨៤៣.៦០៣ដុល្លារអាមេរិក**

### គោលដៅ

ពង្រឹងសិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្រីក្រនៅជនបទដែលខ្វះដីនិងគ្មានដី ដើម្បីឲ្យពួកគាត់ទទួលបាននូវជីវភាពរស់នៅកាន់តែប្រសើរឡើង តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចតាមបែបចូលរួម។

### ទិសដៅ

សាកល្បងអនុវត្តវិធីសាស្ត្រយកសិទ្ធិជាមូលដ្ឋានតាមរយៈការធ្វើផែនការ និងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលគ្មានដីនិងខ្វះដី តាមរយៈការអភិវឌ្ឍជនបទចម្រុះ។

### វិធីសាស្ត្រ

អង្គការជីវិតថ្លៃថ្នូរប្រើវិធីសាស្ត្រយកសិទ្ធិជាមូលដ្ឋានរបស់ខ្លួនដើម្បីសម្រេចគោលដៅរួមរបស់គម្រោងនេះ។

## លទ្ធផលរំពឹងទុក ក្រុមគោលដៅ តំបន់គោលដៅ

### លទ្ធផលរំពឹងទុក

- សហគមន៍និងក្រុមប្រឹក្សាឃុំត្រូវបានពង្រឹងសិទ្ធិអំណាចនិងបានរៀបចំផែនការសម្បទានដីសង្គមកិច្ច បានជួយសម្របសម្រួលដល់អាជ្ញាធរក្នុងការអនុម័តផែនការទាំងនេះ និងចែកដីជូនដល់មុខសញ្ញាអ្នកទទួលដី។
- ប្រជាពលរដ្ឋក្រីក្រដែលគ្មានដីនិងខ្វះដីប្រហែល ១.៣០០ គ្រួសាររស់នៅក្នុងខេត្តកំពង់ស្ពឺនិងកំពង់ឆ្នាំងនឹងទទួលបានផលពីគម្រោងនេះ។
- គ្រួសារនីមួយៗនឹងទទួលបានដីទំហំ ៣០ម៉ែត្រ គុណនឹង ៥០ម៉ែត្រ សម្រាប់សាងសង់លំនៅដ្ឋាន និងដីសម្រាប់ធ្វើកសិកម្មទំហំ ១ហិចតាក្នុងមួយគ្រួសារសម្រាប់គ្រួសារដែលត្រូវទទួលបានដីនៅក្នុងខេត្តកំពង់ឆ្នាំង និង ១,៥ហិចតាក្នុងមួយគ្រួសារសម្រាប់គ្រួសារដែលត្រូវទទួលបានដីនៅក្នុងខេត្តកំពង់ស្ពឺ។

### ក្រុមគោលដៅ

ក្រុមគោលដៅសំខាន់របស់គម្រោងនេះ រួមមានដូចខាងក្រោម ៖

**ថ្នាក់ភូមិ**

- មេភូមិ
- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
- មុខសញ្ញាអ្នកទទួលដី

**ថ្នាក់ឃុំ**

- ក្រុមប្រឹក្សាឃុំ
- ក្រុមការងារថ្នាក់ស្រុក

### តំបន់គោលដៅ

គម្រោងនេះនឹងត្រូវអនុវត្តនៅក្នុងតំបន់គោលដៅចំនួនពីរ ស្ថិតនៅក្នុងស្រុកឱរ៉ាល់និងភ្នំស្រួចនៃខេត្តកំពង់ស្ពឺ និងស្រុកសាមគ្គីមានជ័យនៃខេត្តកំពង់ឆ្នាំង។

Funded by

World Bank JSDF

LIFE WITH DIGNITY
#37, St. 592, P.O Box 37,
Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh
Tel: 855-23-881 100 / 855-23-883 254 / 855-23-883 264
Fax: 855-23-881 616
E-mail: info@lwd.org.kh | Website: www.lwd.org.kh

ជីវិតថ្លៃថ្នូរ
LIFE WITH DIGNITY

# គម្រោងពង្រឹងសិទ្ធិអំណាចសហគមន៍ តាមរយៈការទទួលបានដីសម្បទានសង្គមកិច្ច




COMMUNITY EMPOWERMENT THROUGH ACCESS TO LAND

## PROJECT SUMMARY

**Community Empowerment Through Access To Land (CETAL)** is a Social Land Concession project being implemented by LWD, funded by the Japan Social Development Fund (JSDF) through the World Bank.

The project consists of three main components:

**Component A**—Public awareness and capacity building for social land concession;

**Component B**—Empowered community and land recipients to manage development process and advocate for their right and obtain improved and sustainable livelihoods;

**Component C**—NGO capacity building, coordination and sharing of lessons learned.

**Time frame: 2008-2013**

**Project Cost : US$ 1,483,603**



## PROJECT GOAL, OBJECTIVE, APPROACH

### GOAL
To build civic engagement to facilitate authorities to provide social concession land for poor families and empower them to improve sustainable livelihoods.

### OBJECTIVE
To pilot a right-based approach through planning and implementation of Social Land Concession program for sustainable poverty reduction of landless and land poor families through an integrated rural development.

### APPROACH
LWD applies its current right-based approach to achieve the overall goal of the project.

### EXPECTED RESULT
- Empowered communities and Commune councils prepared the social land concession plans, facilitated authorities to approve them and allocate land to target land recipients.
- About 1,300 landless and land poor families living in Kampong Speu and Kampong Chhnang provinces are expected to benefit from the project.
- Each family will get a land of 30m by 40m for residence and an agricultural land of 1 hectare for selected land recipients in Kampong Chhnang and 1.5 hectares for those in Kampong Speu.



## FOCUS GROUPS, TARGET AREAS

The primary focus groups of the project include the followings:

### VILLAGE LEVEL
Village leaders
Village development committees
Target land recipients

### COMMUNE LEVEL
Commune councils
District working group

### TARGET AREAS
The project covers two locations—Kampong Speu's Aoral and Phnom Sruoch districts, and Kampong Chhnang's Sameakki Meanchey district.

